# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Dec-2012, 10:03
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើបន្ថែមរបស់ អៀង សារី សុំឲ្យអ្នកជំនាញមានគុណវុឌ្ឍិពិនិត្យសុខភាពជាប្រចាំថ្ងៃ ទាក់ទងនឹងសមត្ថភាពរបស់លោក អៀង សារី ដើម្បីជួយការពារខ្លួនឯង ឬតាមជម្រើសផ្សេង សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យគ្រូពេទ្យ អ.វ.ត.ក ធ្វើការសង្កេតជាក់លាក់ទាក់ទងនឹងសមត្ថភាពរបស់លោក អៀង សារី ដើម្បីជួយការពារខ្លួនឯង**

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | |
| | ចៅក្រម យូរ ឧត្តរា | មេធាវីការពារក្ដីជនជាប់ចោទ: |
| | | លោក សុន អរុណ |

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | លោក Michiel PESTMAN |
| លោក ពេជ អង្គ | លោក Victor Koppe |
| Elisabeth SIMONNEAU FORT | លោក អាង ឧត្តម |
| | លោក Michael |
| | លោកG.KARNAVAS |
| | លោក គង់ សំអុន |
| | លោកស្រីAnta GUISSÉ |
| | លោក Arthur VERCKEN |
| | លោក Jacques VERGÈS |

# I. សេចក្តីផ្តើម និង ការសង្ខេបជាបឋម

១. នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់អះអាងអំពីការរកឃើញពីមុនរបស់ខ្លួនថា ជនជាប់ចោទ អៀង សារី អាចចូលរួមប្រកបដោយអត្ថន័យនៅក្នុងសវនាការជំនុំជម្រះសំណុំរឿង ០០២/១ និងថាដូច្នេះ គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[1]។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំឲ្យអង្គភាពពេទ្យ និងអង្គភាពមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក អនុវត្តចំពោះការស្នាក់នៅជាក់លាក់មួយចំនួន តាមអនុសាសន៍ដែលបានផ្តល់ដោយអ្នកជំនាញខាងវេជ្ជសាស្ត្ររបស់អង្គជំនុំជម្រះដើម្បីធានាចំពោះភាពសុខស្រួល និងការគ្រប់គ្រងសុខភាពរបស់ជនជាប់ចោទឲ្យបានសមស្រប[2]។ វិធានការមួយបែបនេះជាសញ្ញាបង្ហាញថា ជនជាប់ចោទបើចាំបាច់អាចត្រូវធ្វើការតាមដានកិច្ចដំណើរការនីតិវិធី ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ជាជាងនៅក្នុងសាលសវនាការ[3]។

២. នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ មេធាវីការពារក្តី អៀង សារី ("មេធាវីការពារក្តី") បានបញ្ជូនសំណើមួយច្បាប់ ជាការគួរសមដោយសុំឲ្យចាប់ផ្តើមនូវវិធានការតាមដាន ខាងវេជ្ជសាស្ត្រខុសៗគ្នា ("សំណើ")[4]។ ដោយរំពឹងទុកថានឹងមានការបន្តសវនាការលើភ័ស្តុតាងនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ សហព្រះរាជអាជ្ញា សូមឆ្លៀតឱកាសនេះដើម្បីផ្តល់ជូននូវចម្លើយតបជាបឋមទៅនឹងសំណើនេះ[5]។ សហព្រះរាជអាជ្ញាសូមរក្សាសិទ្ធិដើម្បីធ្វើការសន្និដ្ឋានបន្ថែមចំពោះបញ្ហានេះ ប្រសិនបើចាំបាច់។

៣. សហព្រះរាជអាជ្ញាសន្និដ្ឋានថា "សំណើជាបន្ទូបន្ទាប់" របស់មេធាវីការពារក្តីសុំឲ្យចាត់តាំងអ្នកជំនាញមួយរូបដើម្បី វាយតម្លៃជារៀងរាល់ថ្ងៃអំពីសមត្ថភាពរបស់ អៀង សារី ក្នុងការចូលរួមសវនាការដើម្បីការពារខ្លួនឯងគឺគ្មានមូលដ្ឋានទេ។ អង្គជំនុំជម្រះបានរកឃើញថា អៀងសារី មាន

---

[1] **E238/9** សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ, ២៦ វិច្ឆិកា ២០១២។

[2] **E238/9** ក្នុងឯកសារដដែលដូចខាងលើ, ត្រង់កថាខណ្ឌ២៩-៣១។

[3] **E238/9** ក្នុងឯកសារដដែលដូចខាងលើ, ត្រង់កថាខណ្ឌ៣៤។

[4] ដាក់ភ្ជាប់មកជាមួយជាឧបសម្ព័ន្ធ I។

[5] បន្ទាប់ពីការបញ្ជូនដើម្បីផ្សព្វផ្សាយជូនជ្រាបនូវចម្លើយតបបឋមរបស់សហព្រះរាជអាជ្ញា ប៉ុន្តែនៅមុនពេលដាក់ឯកសារនេះជាផ្លូវការមេធាវីការពារក្តីបានដាក់នូវសំណើរបស់ពួកគេ។ ឯកសារលេខ **E255** សំណើបន្ថែមរបស់ អៀង សារី សុំឲ្យអ្នកជំនាញដែលមានសមត្ថភាពធ្វើការពិនិត្យវេជ្ជសាស្ត្រប្រចាំថ្ងៃ ទាក់ទិននឹងសមត្ថភាពរបស់លោក អៀង សារី ដើម្បីជួយក្នុងការការពារខ្លួនគាត់ផ្ទាល់ឬម៉្យាងទៀត សំណើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យវេជ្ជបណ្ឌិតរបស់ អ.វ.ត.ក ធ្វើការអង្កេតជាក់លាក់ទាក់ទិននឹងសមត្ថភាពរបស់លោក អៀង សារី ដើម្បីជួយក្នុងការការពារខ្លួនគាត់ផ្ទាល់ ចុះថ្ងៃទី១២ ធ្នូ ២០១២(ដែលបានជូនដំណឹងកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២)។

សម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានការពិនិត្យជាទូទៅលើជនជាប់ចោទ ដោយអ្នកជំនាញវេជ្ជសាស្ត្រអន្តរជាតិ កាលពីថ្ងៃទី៥ និងទី៦ ខែវិច្ឆិកា ឆ្នាំ២០១២ រួចមក។ គ្មានព័ត៌មានថ្មី ត្រូវបានដាក់ដើម្បីទទួលបានការអនុញ្ញាតឲ្យមានការពិនិត្យឡើងវិញទៅលើសម្បទារបស់ អៀង សារី ឡើយ។

៤. តាមពិត តុលាការនៅតែស្ថិតក្រោមកាតព្វកិច្ចដើម្បីតាមដានលក្ខខណ្ឌសុខភាពរបស់ អៀង សារី និងថាអាស្រ័យដោយមូលហេតុនេះហើយដែលគួរបន្តទទួលរបាយការណ៍ ពីអង្គភាពពេទ្យរបស់ អ.វ.ត.ក។ ដូចសហព្រះរាជអាជ្ញាបានបញ្ជាក់ក្នុងតុលាការ គឺថារបាយការណ៍របស់អង្គភាពពេទ្យរបស់ អ.វ.ត.ក ត្រូវតែមានភាពលម្អិតគ្រប់គ្រាន់ដើម្បីធានាថា អង្គជំនុំជម្រះ បានទទួលព័ត៌មានយ៉ាងត្រឹមត្រូវអំពីសុខភាពជារួមរបស់ អៀង សារី និងអំពីការប្រែប្រួលដ៏សំខាន់ណាមួយ នៅចំពោះលក្ខខណ្ឌសុខភាពរបស់គាត់។ ខណៈដែលរបាយការណ៍បែបនេះ គួរមានសេចក្ដីសង្កេត និងយោបល់របស់អង្គភាពពេទ្យ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ផ្ទុយទៅនឹងការសន្និដ្ឋាន របស់មេធាវីការពារក្ដីរបាយការណ៍ទាំងនេះមិនចាំបាច់ត្រូវធ្វើឡើង “ជាបន្តបន្ទាប់”[6]ឬ “ពេញមួយថ្ងៃ”[7]។ សហព្រះរាជអាជ្ញាសន្និដ្ឋានបន្ថែមថា“ការសង្កេតរបស់ក្រុមមេធាវីការពារក្ដីអៀង សារី”[8] មិនពាក់ព័ន្ធ នឹងការវិភាគសត្យានុម័តអំពីលក្ខខណ្ឌវេជ្ជសាស្ត្ររបស់ អៀង សារី ដែរ។

៥. តាមការរកឃើញអំពីសម្បទានាពេលថ្មីៗនេះ គោលបំណងក្នុងការសង្កេតវេជ្ជសាស្ត្រប្រចាំថ្ងៃ គួរតែធ្វើឡើងដើម្បីតាមដានសុខភាពរបស់ អៀង សារី និងចំណុចពាក់ព័ន្ធនឹង<u>ការផ្លាស់ប្ដូរជាសំខាន់</u>ណាមួយដែលអាចនឹងប៉ះពាល់ដល់*សមត្ថភាព* របស់គាត់ក្នុងការចូលរួមដើម្បីការពារខ្លួនគាត់ (មិនមែនការចូលរួមប្រចាំម៉ោងរបស់គាត់ ដូចមេធាវីការពារក្ដីលើកឡើងទេ)។ សូម្បីតែក្នុងបរិបទនៃការវាយតម្លៃអំពី*សម្បទាក្នុងការចូលរួមសវនាការ* ក៏ដោយ ក៏គេគ្មានលក្ខខណ្ឌតម្រូវដើម្បីធ្វើការវាស់ស្ទង់ពីសមត្ថភាពរបស់ជនជាប់ចោទ ក្នុងការតាមដានកិច្ចដំណើរការនីតិវិធីពីមួយនាទីទៅមួយនាទីនោះទេ។ ដូចអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានថ្លែងនៅក្នុងករណីរឿងក្ដី *Strugar* ថាបទដ្ឋានច្បាប់ដែលពាក់ព័ន្ធពិនិត្យទៅលើ “សមត្ថភាពរបស់ជនជាប់ចោទក្នុងការអនុវត្ត

[6] សំណើ, ត្រង់កថាខណ្ឌ៧។

[7] សំណើ, ត្រង់កថាខណ្ឌ៧។

[8] សំណើ, ត្រង់កថាខណ្ឌ៧។

សិទ្ធិរបស់ខ្លួនដែលមានចែងច្បាស់លាស់ និងមិនមានចែងច្បាស់លាស់”[9] និងថា “លក្ខខណ្ឌកម្រិតនឹងត្រូវបានបំពេញនៅពេលណាជនជាប់ចោទមានសមត្ថភាពទាំងអស់នេះ ដែលត្រូវបានគេមើលឃើញជារួម និងតាមរបៀបដែលមានហេតុផលនិងសុភវិនិច្ឆ័យជាកម្រិតមួយដែលអាចឲ្យជនជាប់ចោទអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីបាន(ក្នុងករណីខ្លះត្រូវការជំនួយ)និងការអនុវត្តបានពេញលេញចំពោះសិទ្ធិដូចបានកំណត់អត្តសញ្ញាណទាំងនេះ មានន័យថាការពារខ្លួនឯង”[10]។

៦. សហព្រះរាជអាជ្ញា នៅចាំបានថាយុត្តិសាស្ត្រអន្តរជាតិជាធរមានស្តីពីសម្បទាក្នុងការចូលរួមសវនាការ បានតម្រូវឲ្យមានការពិចារណាថាតើជនជាប់ចោទមាន ឬ ពុំមាន៖

(១) *ការយល់ឃើញដោយវិចារណញ្ញាណ ក៏ដូចជាការយល់ឃើញទៅលើអង្គហេតុនៃបទចោទប្រឆាំងនឹងគាត់។*

(២) *ការយល់ឃើញ ដោយវិចារណញ្ញាណ ក៏ដូចជាការយល់ឃើញទៅលើចរឹកលក្ខណៈ និងប្រធានបទនៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់។ និង*

(៣) *សមត្ថភាពបច្ចុប្បន្នក្នុងការពិគ្រោះយោបល់ជាមួយមេធាវីរបស់គាត់ និងក្នុងការជួយរៀបចំកិច្ចការពារខ្លួន ក្នុងកម្រិតនៃការយល់ឃើញដោយវិចារណញ្ញាណដ៏សមហេតុសមផលមួយ*[11]។

៧. ការណ៍នេះ ពុំមែនសមមូលទៅនឹង “សមត្ថភាពក្នុងការ*យល់ដឹងទាំងស្រុង* ទៅលើកិច្ចដំណើរការនីតិវិធីនៅក្នុងសវនាការនោះទេ”[12] ហើយក៏មិនចាំបាច់ដើម្បីកំណត់ថា ជនជាប់ចោទម្នាក់ “បានប្រព្រឹត្តនៅក្នុងកម្រិតដ៏ខ្ពស់មួយនៃដំណើរការ” នោះក៏ទេដែរ។ ផ្ទុយទៅវិញ ការសាកល្បងនេះគឺដើម្បីរកមើលថា តើចុងចោទបានឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវអប្បបរមាមួយចំនួនទាំងនេះ

---

[9] *រដ្ឋអាជ្ញា ទល់នឹង Pavle Strugar*, សំណុំរឿងលេខ: IT-01-42-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ស្នើឲ្យបញ្ចប់កិច្ចដំណើរការនីតិវិធី, ២៦ ឧសភា ២០០៤, កថាខណ្ឌ៣៦។

[10] *រដ្ឋអាជ្ញា ទល់នឹង Pavle Strugar*, សំណុំរឿងលេខ: IT-01-42-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ស្នើឲ្យបញ្ចប់កិច្ចដំណើរការនីតិវិធី, ២៦ ឧសភា ២០០៤, កថាខណ្ឌ៣៧ (សង្កត់ន័យត្រង់ពាក្យដែលមានគូសបន្ទាត់ពីក្រោម)។

[11] ករណី *អគ្គព្រះរាជអាជ្ញារងសម្រាប់ឧក្រិដ្ឋកម្មកម្រិតធ្ងន់ ទល់នឹង Josep Nahak*, ការយល់ឃើញ និង ដីកាបង្គាប់ស្តីពីសមត្ថកិច្ចចូលរួមសវនាការរបស់ចុងចោទឈ្មោះ Nahak, ថ្ងៃទី១ ខែមីនា ឆ្នាំ២០០៥, កថាខណ្ឌទី៥២។ សូមអានផងដែរ ករណី *រដ្ឋអាជ្ញា ទល់នឹង Vladimir Kovačević*, សំណុំរឿងលេខ IT-01-42/2-I, សំណៅសាធារណៈ: ស្តីពីសេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទក្នុងការធ្វើសំអាង និងចូលរួមសវនាការ, ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៦, កថាខណ្ឌទី៥។

[12] ករណី *រដ្ឋអាជ្ញា ទល់នឹង Pavle Strugar*, សំណុំរឿងលេខ IT-01-42-T, សេចក្តីសម្រេច យោង: ញត្តិរបស់មេធាវីការពារក្តីស្នើសុំបញ្ចប់កិច្ចដំណើរការនីតិវិធី, ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤, កថាខណ្ឌទី៤៨។

ហើយឬនៅ ដែលថាបើពុំអាចឆ្លើយតបបានទេ គេមិនអាចធ្វើការពិចារណាថា គាត់មានសម្បទាក្នុងការចូលរួមសវនាការបានឡើយ[13]។ នៅក្នុងការវាយតម្លៃលើសមត្ថភាពរបស់ជនជាប់ចោទចំពោះការអនុវត្តនូវសិទ្ធិរបស់គាត់ ដើម្បីទទួលបាននូវការជំនុំជម្រះក្តីដ៏ត្រឹមត្រូវនោះ វាក៏ជាការមួយដ៏សមស្របផងដែរដែលត្រូវធ្វើការពិចារណាថា ជនជាប់ចោទត្រូវបានតំណាងដោយមេធាវីការពារក្តី "ហើយនៅក្នុងករណីដោយឡែកណាមួយ ដែលអាចនឹងធ្វើការប៉ះប៉ូវបានយ៉ាងគ្រប់គ្រាន់ចំពោះការខ្វះខាតខាងសមត្ថភាពពាក់ព័ន្ធណាមួយ"[14]។ ជាក់ស្តែងមេធាវីការពារក្តីត្រូវមានកាតព្វកិច្ចជួយកូនក្តីរបស់ខ្លួន ពុំមែនគ្រាន់តែនៅអកម្ម និង មិនបានជួយសម្រួលដល់កូនក្តីរបស់ខ្លួនឲ្យមានការយល់ដឹងពីកិច្ចដំណើរការនីតិវិធី នោះឡើយ។

៨. ដូចដែលបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះបានរកឃើញថា អៀង សារី មានសម្បទាក្នុងការចូលរួមសវនាការ។ ឥឡូវនេះ មេធាវីការពារក្តីកំពុងស្វែងរកធ្វើការប្តឹងផ្តល់សារជាថ្មីនៅលើបញ្ហាសម្បទានេះ ដោយផ្អែកលើមូលដ្ឋាននៃការអនុវត្តមិនបានត្រឹមត្រូវនូវច្បាប់ពាក់ព័ន្ធ និង អវត្តមាននៃការផ្លាស់ប្តូរណាមួយខាងផ្នែកច្បាប់ នៅក្នុងកាលៈទេសៈដែលបានលើកឡើងនេះ។ អាស្រ័យហេតុដូច្នេះ គេគួរបដិសេធសំណើនេះចោល។

៩. ជាងនេះទៀត សហព្រះរាជអាជ្ញាចាត់ទុកថា ការថត(សម្លេង/រូបភាពវីដេអូ) អំពីការពិគ្រោះយោបល់របស់ខ្លួនជាមួយនឹងបុគ្គលិកដែលបម្រើការនៅក្នុងអង្គភាពពេទ្យរបស់អវតកគឺមិនមានការអនុញ្ញាតទេ ហើយដែលអាចបង្កើតបានទៅជាការជ្រៀតជ្រែកចូលនៅក្នុងយន្តការរបស់អង្គជំនុំជម្រះ ដែលបានដាក់ឲ្យដំណើរការសម្រាប់តាមដានអំពីស្ថានភាពសុខភាពរបស់ អៀង សារី។ ក្រុមមេធាវីការពារក្តីរបស់ អៀង សារី ត្រូវបានអនុញ្ញាតឲ្យយកចូលនូវឧបករណ៍សំរាប់ថតសម្លេង និងរូបភាពវីដេអូ ទៅក្នុងមន្ទីរឃុំឃាំងតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១១។ ការអនុញ្ញាតនោះបានពង្រីកបន្ថែមរហូតដល់អនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីថត(សម្លេង/រូបភាពវីដេអូ) អំពីការ *ធ្វើសម្ភាសន៍របស់ពួកគេជាមួយកូនក្តីរបស់*

[13] ករណី *អគ្គព្រះរាជអាជ្ញារងសម្រាប់ឧក្រិដ្ឋកម្មកម្រិតធ្ងន់ ទល់នឹង Josep Nahak*, ការយល់ឃើញ និង ដីកាបង្គាប់ស្តីពីសមត្ថកិច្ចចូលរួមសវនាការរបស់ចុងចោទឈ្មោះ Nahak, ថ្ងៃទី១ ខែមីនា ឆ្នាំ២០០៥, កថាខណ្ឌទី១២១។

[14] ករណី *រដ្ឋអាជ្ញា ទល់នឹង Vladimir Kovačević,* សំណុំរឿងលេខ IT-01-42/2-I, សំណៅសាធារណៈ ស្តីពីសេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទក្នុងការធ្វើសំអាង និងចូលរួមសវនាការ, ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៦, កថាខណ្ឌទី២៣។

*ពួកគេទៅទៀត* ដើម្បីជួយដល់ការត្រៀមរៀបចំសំរាប់ការការពារក្តី និងដើម្បីជួសំរួលដល់ការប្រាស្រ័យទាក់ទងរវាង អៀង សារី និងមេធាវីការពារក្តីរបស់ពួកគេ[15]។

១០. មេធាវីការពារក្តី អៀង សារី បានធ្វើហួសពីវិសាលភាពនៃសិទ្ធិអំណាចនោះ ហើយបានពាក់ព័ន្ធទៅក្នុងការថតខ្សែអាត់សម្លេងនូវបទសម្ភាសន៍ជាមួយបុគ្គលពេទ្យ។ ការណ៍នេះអាចថា បានជ្រៀតជ្រែកក្នុងការបំពេញមុខងារយ៉ាងត្រឹមត្រូវរបស់អង្គភាពពេទ្យ។ វាអាចជាការជ្រៀតជ្រែកមួយទៅលើសាក្សីសក្តានុពល ដរាបណាបុគ្គលិកពេទ្យរូបនោះ មិនអាចត្រូវបានកោះអញ្ជើញឲ្យមកផ្តល់ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា មេធាវីការពារក្តីថ្មីៗនេះត្រូវបានព្រមានដោយអនុលោមតាមវិធាន៣៨ ថាត្រូវបានហាមឃាត់មិនឲ្យបំពេញកិច្ចស៊ើបសួរឡើយនិងថាបើមានការរំលោភបទប្បញ្ញត្តិនេះអាចនឹងនាំឲ្យមានការអនុវត្តនូវការដាក់ទណ្ឌកម្ម[16]។

១១. មិនមែនជាតួនាទីរបស់ក្រុមមេធាវីការពារក្តី ដែលត្រូវធ្វើការស៊ើបសួរជាន់គ្នាមួយទៀតនោះទេ តាមរយៈទាមទារសុំថតសម្លេងកិច្ចសម្ភាសន៍ជាមួយបុគ្គលិកពេទ្យ ដែលត្រូវបានស្នើសុំដោយអង្គជំនុំជម្រះដើម្បីរាយការណ៍ឲ្យខ្លួន។ នៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ក្រុមមេធាវីការពារក្តីមានសិទ្ធិក្នុងការស្វែងរកព័ត៌មានដូចជា អំពីសុខមាលភាពនៃកូនក្តីរបស់ខ្លួន។ ក្រុមមេធាវីការពារក្តីក៏មានសិទ្ធិក្នុងការស្នើសុំទៅអង្គជំនុំជម្រះផងដែរ ដូចជាអំពីប្រភេទនានានៃព័ត៌មាន ដែលគួរត្រូវបានដាក់បញ្ចូលនៅក្នុងរបាយការណ៍ស្តីពីសុខភាពប្រចាំថ្ងៃរបស់អង្គភាពពេទ្យ។ ក៏ប៉ុន្តែ ការចូលរួមនៅក្នុងការស៊ើបសួរដោយគ្មានការអនុញ្ញាត គ្រាន់តែដោយសារក្រុមមេធាវីការពារក្តី មិនយល់ព្រមជាមួយ នឹង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតែប៉ុណ្ណោះនោះ គឺជាការប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ ស្តីពីការទទួលខុសត្រូវរបស់មេធាវី។

## II. **ដំណោះស្រាយតាមផ្លូវច្បាប់ដែលបានស្នើសុំ**

១២. នៅពេលដែល សហព្រះរាជអាជ្ញាថ្លែងបញ្ជាក់ជាថ្មីឡើងវិញដដែលៗថា សំណើរបស់ក្រុមមេធាវីការពារក្តីអៀង សារីដែលសុំឲ្យធ្វើវាយតម្លៃជាថ្មីឡើងវិញប្រចាំថ្ងៃលើបញ្ហាខាងកាយសម្បទា និង

---

[15] ឯកសារលេខA371/2/12 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសំរេចបដិសេធលើសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូ នៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង, ចុះថ្ងៃទី១១ មិថុនា ឆ្នាំ២០១០, ត្រង់កថាខណ្ឌទី២៨, និងទី៣៣-៣៥។

[16] **E251** សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលអាចឲ្យមានការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ (ឯកសារ E221, E223, E224, E224/2, E234, E234/2, E241 និង E241/1), ៧ ធ្នូ ២០១២, ត្រង់កថាខណ្ឌ៣៨។

ខាងសតិបញ្ញាស្មារតីក្នុងការតាមដានកិច្ចដំណើរការនីតិវិធីសវនាការ នៅគ្រប់ពេលទាំងអស់នោះ គឺមិនមានមូលដ្ឋានត្រឹមត្រូវទេ។ សហព្រះរាជអាជ្ញា យល់ថា របាយការណ៍ប្រចាំថ្ងៃរបស់អង្គភាពពេទ្យនៃ អវតក ស្តីពីស្ថានភាពសុខភាពរបស់ អៀង សារី គួរបានដាក់បញ្ចូលនូវព័ត៌មានឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យអង្គជំនុំជម្រះអាចតាមឃ្លាំមើលអំពីស្ថានភាពជារួមទាំងមូលរបស់គាត់ និងដើម្បីបញ្ជាក់អំពីបញ្ហាមួយចំនួនដែលអាចតម្រូវឱ្យតុលាការធ្វើការឆ្លើយតប។ សហព្រះរាជអាជ្ញា មិនបានទទួលនូវនូវសេចក្តីចម្លងនៃរបាយការណ៍ទាំងនេះទេ ប៉ុន្តែសូមជូនជាយោបល់ដើម្បីពិចារណាថា អង្គជំនុំជម្រះគួរតម្រូវឱ្យដាក់បញ្ចូលនៅក្នុងរបាយការណ៍ខាងលើ នូវប្រភេទនៃព័ត៌មានមួយចំនួនដូចខាងក្រោមនេះ៖

ក. សេចក្តីសង្ខេបមួយស្តីពីស្ថានភាពខាងផ្លូវកាយនិងខាងសតិបញ្ញាស្មារតីជារួមទាំងមូលរបស់ អៀង សារីប្រចាំថ្ងៃ។

ខ. សេចក្តីសង្កេតថា តើជាទូទៅ អៀង សារី អាចមានសមត្ថភាពក្នុងការតាមដានដំណើរការនីតិវិធីសវនាការបានដែរ ឬទេ? (យល់ថាតើគេកំពុងតែនិយាយអំពីអ្វី? ហើយអ្នកណាជាអ្នកនិយាយ?) នៅពេលដែលគាត់ភ្ញាក់ឡើង។

គ. សេចក្តីសង្កេតអំពីថាតើ អៀង សារី អាចមានសមត្ថភាពធ្វើការប្រាស្រ័យទាក់ទងជាមួយមនុស្សទាំងឡាយដែលនៅជុំវិញគាត់ (លើកឡើងនូវសំណើរបស់គាត់ និងយល់ពីចម្លើយតបរបស់អ្នកទាំងឡាយដែលគាត់កំពុងតែប្រាស្រ័យទាក់ទងជាមួយ)បានដែរឬទេ?។ និង

ឃ. លើកឡើងនូវអនុសាសន៍អំពីថា តាមការយល់ឃើញអំពីសេចក្តីត្រូវការចាំបាច់សម្រាប់សុខភាពនិងភាពសុខស្រួលរបស់ អៀង សារី តើការឱ្យគាត់ស្នាក់អាស្រ័យនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ឬនៅក្នុងសាលសវនាការ ណាមួយប្រសើរ ជាង?

១៣. សហព្រះរាជអាជ្ញា សូមស្នើដោយគោរព សូមមេត្តាផ្តល់នូវសេចក្តីចម្លងនៃរបាយការណ៍ប្រចាំថ្ងៃប្រយោជន៍ដើម្បីឱ្យខ្លួនអាចធ្វើការឆ្លើយតប ប្រកបដោយអត្ថន័យ ទៅនឹងសំណើសុំណាមួយ ដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តី ស្តីពីបញ្ហាសមត្ថភាពរបស់អៀង សារី ក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនៃសវនាការដោយមានជំនួយពីមេធាវីការពារក្តី។

១៤. ជាចុងក្រោយ សហព្រះរាជអាជ្ញា យល់ឃើញថាដើម្បីភាពប្រយ័ត្នប្រយែង អង្គជំនុំជម្រះត្រូវតែងតាំងអ្នកជំនាញខាងវេជ្ជសាស្ត្រឯករាជ្យណាម្នាក់ (ដូចជាលោក វេជ្ជបណ្ឌិត Campbell ជាដើម ដែលជាអ្នកជំនាញដែលធ្លាប់ដឹងច្បាស់ជាងគេបំផុតអំពីស្ថានភាពសុខភាពរបស់ អៀង សារី) ដើម្បីពិនិត្យមើលឡើងវិញអំពីស្ថានភាពសុខភាពជារួមទាំងមូលរបស់ អៀងសារី ជាទៀងទាត់តាមកាលកំណត់ (ឧទាហរណ៍ដូចជា រៀងរាល់បីខែម្តង) ឬមួយក៏ នៅពេលដែលមានការផ្តល់ការណែនាំពីអង្គភាពពេទ្យរបស់ អវតក ថាការវាយតម្លៃបែបនេះគឺមានសារៈប្រយោជន៍។ ដើម្បីជៀសវាងនូវការមន្ទិលសង្ស័យ សហព្រះរាជអាជ្ញា *មិនធ្វើ* អនុសាសន៍ថា ការពិនិត្យឡើងវិញបែបនេះ គួរតែជាការវាយតម្លៃឡើងវិញទៅលើសមត្ថភាពរបស់ អៀង សារី ដើម្បីអនុវត្តនូវសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវនោះឡើយ។ គោលបំណងសំខាន់បំផុតនៃការពិនិត្យឡើងវិញតាមកាលកំណត់ជាទៀងទាត់នោះ គឺដើម្បីធានាឲ្យប្រាកដថា សេចក្តីត្រូវការចាំបាច់ក្នុងការពិនិត្យសុខភាពរបស់ អៀង សារី ត្រូវបានចាត់ចែងគ្រប់គ្រងតាមវិធីមួយដ៏ល្អប្រសើរបំផុតតាមដែលអាចធ្វើទៅបាន ហើយថាសេចក្តីការណែនាំបន្ថែមរបស់អ្នកជំនាញ គឺមានសម្រាប់ផ្តល់ជូន អង្គជំនុំជម្រះ ជាទៀងទាត់៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |